# សំណុំរឿងមួយទៀត



## ការពិនិត្យឡើងវិញលើសំណុំរឿង ០០២/០២

ដោយ ខេតលីន កាហ្វ្រៀ (Caitlin McCaffrie) និង

ដាញៀ៉ល ម៉ាតើស (Daniel Mattes)

ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១៨

EAST-WEST CENTER

WSDHANDACENTER FOR HUMAN RIGHTS & INTERNATIONAL JUSTICE Stanford University

KRT Monitor Special Report

# សំណុំរឿងមួយទៀត

## ការពិនិត្យឡើងវិញលើសំណុំរឿង ០០២/០២: ការជំនុំជម្រះដំណាក់កាលទីពីរ

## ប្រឆាំងលើជនជាប់ចោទ

## លោក នួន ជា និងលោកខៀវ សំផន

## ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ដោយ ខេតលីន កាហ្វហ្វ្រៀ (Caitlin McCaffrie)

និង

ដាញ៉េល ម៉ាតេស (Daniel Mattes)

របាយការណ៍សម្រាប់មជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា

(WSD Handa Center) សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ

នៅសាកលវិទ្យាល័យស្ទែនហ្វដ

និងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center)

# កាលប្បវត្តិនៃព្រឹត្តិការណ៍សំខាន់

| | |
|---|---|
| ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៧ | សហចៅក្រមស៊ើបអង្កេត សម្រេចឃុំខ្លួនលោក នួន ជា ហើយត្រូវ បញ្ជូនទៅកាន់មន្ទីរឃុំឃាំងរបស់អ.វ.ត.កដោយត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និង ឧក្រិដ្ឋកម្មក្រោមក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ របស់កម្ពុជា |
| ថ្ងៃទី ១៤ ខែ វិច្ឆិកា ២០០៧ | លោកអៀង សារី និងអ្នកស្រីអៀង ធីរិទ្ធត្រូវបានឃុំខ្លួននិងចោទ ប្រកាន់ពីបទឧក្រិដ្ឋដូចគ្នា |
| ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ | លោកខៀវ សំផនត្រូវបានឃុំខ្លួន និងចោទប្រកាន់ពីបទឧក្រិដ្ឋដូចគ្នា |
| ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១០ | សហចៅក្រមស៊ើបអង្កេតបញ្ចប់ការស៊ើបសួរ ក្នុងសំណុំរឿង ០០២ |
| ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១០ | សហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ |
| ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០១១ | សវនាការបឋមនៅក្នុងសំណុំរឿង ០០២ |
| ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០១១ | អង្គជំនុំជម្រះចេញសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកដំបូងដែលកំណត់ពីវិសាលភាពនៃសំណុំរឿង ០០២/០១ |
| ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០១១ | អ្នកស្រី អៀង ធីរិទ្ធបានកាត់ផ្តាច់ជាផ្លូវការពីដំណើរការនីតិវិធីបន្ទាប់ ពីរកឃើញថាពុំមានសម្បទាអាចចូលរួមជំនុំជម្រះបានទេ ដោយសារ បញ្ហាសុខភាពនៅថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១១ |
| ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០១១ | សវនាការលើភស្តុតាងចាប់ផ្តើមនៅក្នុងសំណុំរឿង ០០២ ជាពិសេស សំណុំរឿង ០០២/០១ |
| ថ្ងៃទី០៨ខែកុម្ភៈឆ្នាំ២០១៣ | អង្គជំនុំជម្រះតុលាការកំពូលច្រានចោលសេចក្តីសម្រេចបំបែកដំណើរ ការនីតិវិធីលើបណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តី និងព្រះរាជ អាជ្ញា |
| ថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៣ | លោក អៀង សារី បានទទួលមរណៈភាពហើយនីតិវិធីប្រឆាំងនឹងរូប គាត់ត្រូវបានបញ្ចប់ |

| | |
|---|---|
| ថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១៣ | អង្គជំនុំជម្រះចេញសេចក្តីសម្រេចលើកទីពីរស្តីពីការបំបែកនីតិវិធី កំណត់ឡើងវិញអំពីវិសាលភាពនៃសំណុំរឿង ០០២/០១ |
| ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០១៣ | អង្គជំនុំជម្រះតុលាការកំពូលគាំទ្រការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីថ្មី |
| ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៣ | សេចក្តីសន្និដ្ឋានបញ្ចប់នៅក្នុងសំណុំរឿង ០០២/០១ |
| ថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៤ | អង្គជំនុំជម្រះចេញសេចក្តីសម្រេចបញ្ជាក់លើវិសាលភាពនៃសំណុំរឿង ០០២/០២ |
| ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០១៤ | អង្គជំនុំជម្រះតុលាការកំពូលគាំទ្រលើការពង្រីកវិសាលភាពថ្មីនៃសំណុំរឿង ០០២/០២ |
| ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០១៤ | សវនាការបឋមក្នុងសំណុំរឿង ០០២/០២ |
| ថ្ងៃទី ០៨ ខែសីហា ឆ្នាំ ២០១៤ | ការប្រកាសសាលក្រមលើសំណុំរឿង ០០២/០១ |
| ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៤ | គ្រោងបើកសវនាការលើភស្តុតាង - ចាប់ផ្តើមធ្វើពហិការមិនចូលរួម<br>ស្តាប់សវនការ របស់ភាគីការពារ |
| ថ្ងៃទី ០៨ ខែមករា ឆ្នាំ ២០១៥ | ថ្ងៃបើកសវនាការពិតប្រាកដត្រូវបានបិទបញ្ចប់ភ្លាមៗដោយសារបញ្ហា សុខភាព របស់លោក ខៀវ សំផន |
| ថ្ងៃទី ២១ ខែមករា ឆ្នាំ ២០១៥ | បន្តសវនាការលើភស្តុតាងក្នុងសំណុំរឿង ០០២/០២ |
| ថ្ងៃទី ០៧-២៧ ខែមិថុនា ឆ្នាំ ២០១៦ | កាំង ហ្គេចអៀវ ហៅឌុច ដែលត្រូវបានផ្តន្ទាទោសក្នុងសំណុំរឿង ០០១ ផ្តល់សក្ខីភាពជាសាក្សីក្នុងសំណុំរឿង ០០២/០២ |
| ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦ | សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ បានប្រកាស ថាទោសជាប់ពន្ធនាគារអស់មួយជីវិតសម្រាប់ចុងចោទទាំងពីរត្រូវ បានអះអាង ទោះបីជាការកាត់ទោសមួយចំនួនត្រូវបាន លុបចោល ឬកែប្រែ។ |
| ថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១៧ | ថ្ងៃបិទបញ្ចប់សវនាការលើភស្តុតាងក្នុងសំណុំរឿង ០០២/០២ |
| ថ្ងៃទី ១៣-២៣ ខែមិថុនា ឆ្នាំ ២០១៧ | សេចក្តីសន្និដ្ឋានបញ្ចប់ក្នុងសំណុំរឿង ០០២/០២ |
| ថ្ងៃទី ១៦ ខែវិច្ឆិកាឆ្នាំ ២០១៨ | សាលក្រមសំណុំរឿង០០២/០២ ត្រូវបានប្រកាសជាទម្រង់សង្ខេប |

# ១. សេចក្តីផ្តើម

នៅថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុង តុលាការ កម្ពុជា (អ. វ. ត. ក) ដែលត្រូវបានគេស្គាល់ថាជាសាលាក្តីខ្មែរក្រហមនឹងចេញ សេចក្តីសង្ខេបនៃ សាលក្រមក្នុង សំណុំរឿង ០០២/០២ ដែលជាការជំនុំជម្រះដំណាក់កាលទីពីរប្រឆាំងនឹង ជនជាប់ ចោទ នួន ជា និងខៀវ សំផន មេដឹកនាំជាន់ខ្ពស់ដែលនៅរស់រានមានជីវិតនៃរបប កម្ពុជាប្រជា ធិបតេយ្យដែលបានគ្រប់គ្រងប្រទេសកម្ពុជាចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៧ ខែមករា ឆ្នាំ ១៩៧៩ ។

ជាមួយនឹងការលើកលែងបទចោទប្រកាន់ចុងក្រោយប្រឆាំងអ្នកស្រី អ៊ឹម ចែម នៅក្នុងសំណុំរឿង ០០៤/០១ ការសម្រេចថ្មីរបស់សហចៅក្រមស៊ើបអង្កេតក្នុងការស៊ើបសួរលើលោក អោ អាន នៅក្នុងសំណុំរឿង ០០៤/០២ និង ភាពមិនច្បា ស់ លាស់នៃការស៊ើបអង្កេតលើលោក មាស មុត ក្នុងសំណុំរឿង ០០៣ និង លោក យឹម ទិត ក្នុងសំណុំរឿង ០០៤ នៅថ្ងៃអនាគត ករណីនេះ ប្រហែលជាសេ ចក្តីវិនិច្ឆ័យចុងក្រោយ ដែលកើតចេញពីអង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក។ អ.វ.ត.ក ត្រូវបានបង្កើតឡើងក្រោមការចរចា អស់រយៈពេលមួយទសវត្សរ៍រវាង រាជរដ្ឋាភិបាល កម្ពុជា និងអង្គការសហប្រជាជាតិ អាចនឹងចាប់ផ្តើម កាត់បន្ថយប្រតិបត្តិការរបស់ខ្លួន ក្រោយកិច្ចដំណើរការ ដំបូងរបស់ខ្លួនអស់ពេលជាងមួយទសវត្សរ៍មកនេះ។ បើទោះជាដំណើរការបណ្តឹងសា ទុក្ខ នៅក្នុងករណីនេះ នៅតែបន្តនោះ។

ដោយមិនគិតពីភាពមិនប្រាកដប្រជានៃសំណុំរឿងនៅសល់នាពេលខាងមុខនោះ គិតត្រឹមថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រ ះសាលាដំបូ ង នឹងសម្រេចបាននូវសមិទ្ធិផលមួយគួរឲ្យកត់ សម្គាល់គឺ ការចេញសេចក្តីសម្រេចបទចោទប្រកាន់អំពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំង នឹងមនុស្សជាតិ និង បទឧក្រិដ្ឋសង្គ្រាម នៅក្នុងសវនាការប្រឆាំ ងនឹងលោកនួន ជា និងលោកខៀវ សំផន។ ខណៈដែល សំណុំរឿង០០១ទទួលបានកោតសរសើរចំពោះប្រសិទ្ធភាព និងការបង្កើតថ្មី របស់ខ្លួន ដោយដាក់បញ្ចូល ជនរងគ្រោះទៅក្នុងដំណើរការតុលាការនោះ គេរដំណែលនៃសំណុំរឿង ០០២ នៅមិនទាន់មានភាព ច្បាស់លាស់នៅឡើយទេ។ សម្រាប់បុគ្គលដែលការពារសាលាក្តីខ្មែរ ក្រហម នឹងលើកឡើងពីភាព ស៊ីជម្រៅនិងភាពស្មុគស្មាញនៃសំណុំរឿង ០០២ ដោយធ្វើការប្រៀប ធៀបអំពីវិសាលភាពរបស់វាទៅនឹង ករណីនៅនូរិមប៊ែក (Nuremberg) ក្រោយសង្គ្រាមលោកលើក ទី២។ បុគ្គលផ្សេងទៀតនឹង ថ្កោលទោស ហើយរិះគន់ដល់ អ.វ.ត.ក ដោយទាញភ្ជាប់ រយៈពេល យូរអង្វែងនៃកិច្ចដំណើរការនីតិវិធីជាង ១១ឆ្នាំចាប់តាំងពីបើកការស៊ើបក្នុងសំណុំរឿង ០០២ជាមួយនឹងការចំណាយលើការបំពេញមុខងាររបស់សាលាក្តីចាប់តាំងពីបើកដំបូង។ មតិវាយប្រហារ និងការពារជុំវិញអ.វ.ត.ក ពិតជាមិនទទួលបានការយកចិត្ត ទុកដាក់ចំពោះអ្វីដែល បានកើតមានឡើង

ពិតប្រាកដនៅក្នុងសាលសវនាការ ឬត្រូវបានសរសេរនៅក្នុងការដាក់ស្នើ និង សេចក្តីសម្រេចឡើយ។ បើទោះជាកេរដំណែលចុងក្រោយរបស់សាលាក្តីខ្មែរក្រហម មិនទាន់មាន ភាពប្រាកដប្រជាក៏ដោយ ប៉ុន្តែវិសាលភាពដ៏ធំទូលាយនៃសក្ខីភាពរបស់សាក្សី និងដើមបណ្តឹង
រដ្ឋប្បវេណី រួមទាំងឯកសារភស្តុតាងដែលបានបង្កើតនៅក្នុងដំណើរការការស៊ើបអង្កេត ការជំនុំ ជម្រះ និងបណ្តឹងសាទុក្ខនានាមិនគួរត្រូវបានគេបំភ្លេចចោលឡើយ។

ហេតុដូច្នេះហើយវាជាប្រការគួរអោយខកចិត្តដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចចេញត្រឹមតែសាលក្រមចុងក្រោយមួយនៅថ្ងៃទី ១៦ ខែវិច្ឆិកាឆ្នាំ ២០១៨ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុង តុលា ការកម្ពុជា (អ.វ.ត.ក) ត្រូវបានបង្កើតឡើងជាផ្នែកមួយដើម្បីធ្វើជាគំរូសម្រាប់ប្រព័ន្ធយុត្តិធម៌ក្នុងស្រុក ដ៏ទន់ខ្សោយនៅកម្ពុជាដែលជារឿយៗតែងតែចេញសេចក្តីវិនិច្ឆ័យឬសាលក្រមដោយគ្មានហេតុផលពេញលេញ។ ការចំណាយពេលវេលា ការពន្យារពេលដោយការលកប្រែ បរិមាណទំព័រ និងភាព ស្មុគស្មាញផ្នែកច្បាប់ក្នុងការសរសេរសាលដីកានៃសំណុំរឿង ០០២/០២ មិនគួរត្រូវបានប្រើជា មូលហេតុដោះសារ សម្រាប់ដំណើរការដែលបានចាប់ផ្តើមតាំងពីឆ្នាំ ២០០៧ នោះមកទេ។
ឱកាសក្នុងការបង្កើតកេរដំណែលពិតប្រាកដរបស់សាលាក្តីត្រូវបានបន្ថយដោយការចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនេះ។

បន្ទាប់ពីបានពិនិត្យតាមដានសវនាការជារៀងរាល់ថ្ងៃអស់ រយៈពេលជាងដប់ឆ្នាំនៅអ.វ.ត.ក កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម រៀបចំចេញរបាយការណ៍ចុងក្រោយលើសំណុំរឿង ០០២/០២ ដើម្បីសង្ខេបខ្លឹមសារនៃការជំនុំជម្រះ និងភ្ជាប់រូបភាពធំទូលាយរួម និងព័ត៌មានលម្អិត ដែលកើតមានឡើងអស់កាលជាង ២៧៤ថ្ងៃ នៃកិច្ចដំណើរការនីតិវិធី។ របាយការណ៍នេះត្រូវបាន ចងក្រងផ្អែកលើកំណត់ត្រាសេចក្តីសង្ខេបនិងទិន្នន័យដែលប្រមូលបានដោយក្រុមឃ្លាំមើលដែល មានវត្តមានជារៀងរាល់ថ្ងៃនៃសវនាការក្នុងសំណុំរឿង ០០២/០២ ។ ចាប់តាំងពីសវនាការបឋមនៃ សំណុំរឿង ០០២/០២ កាលពីខែកក្កដាឆ្នាំ ២០១៤ មកក្រុមអ្នកឃ្លាំមើលបានសសេរ របាយ ការណ៍ប្រចាំសប្តាហ៍ចំនួន ៨០ រហូតដល់ពេលបិទបញ្ចប់ការផ្តល់អំណះអំណាង (ទឡ្ហីករណ៍) កាលពីខែមិថុនា ឆ្នាំ ២០១៧ ។ របាយការណ៍នេះមានបំណងផ្តល់សំណុំរឿងពេញលេញ នៅក្នុងឯកសារតែមួយ ហើយឆ្លុះបញ្ចាំងពីការកាត់សេចក្តីក្នុងបរិបទទូលំទូលាយរបស់ អ.វ.ត.ក រួមទាំងសំណុំរឿង ០០១ និង ០០២/០១ ។

របាយការណ៍សង្ខេបនេះ ចែកចេញជាពីរផ្នែកសំខាន់ៗ: ផ្នែកដំបូង សង្ខេបពីសក្ខីកម្ម និងភស្តុតាង ដែលបានដាក់បង្ហាញនៅក្នុងសាលសវនាការ ក្នុងរយៈពេលជិតពីរឆ្នាំនៃសវនាការលើភស្តុតាង។ ផ្នែកទីពីលើកឡើងពីបញ្ហាផ្លូវច្បាប់ឬនីតិវិធីចំនួន ៦ ដែលអ្នកនិពន្ធនិងក្រុមត្រួតពិនិត្យបានកំណត់ ឃើញថាមានភាពត្រឹមត្រូវបំផុត។ របាយការណ៍នេះ មិនសំដៅផ្តល់យោបល់ ឬការណែនាំណាមួយ ដល់សាលាក្តីខ្មែរក្រហម

ឬស្ថាប័នណាផ្សេងឡើយ។ អ្នកនិពន្ធសង្ឃឹមថា វាអាចជាឧបករណ៍ជួយ ដល់អ្នកដែលចាប់អារម្មណ៍ លើព័ត៌មានលម្អិតក្នុងសំណុំរឿង ០០២/០២: រឿងរ៉ាវពីសាក្សី ដែល ប្រហែលជាមិនដែលបានចែករំលែកជាសាធារណៈពីមុនការធ្វើតេស្តទៅតាមបទដ្ឋានច្បាប់អន្តរជាតិ និងការពិតមួយចំនួនដែលមានសរសេរនៅក្នុងប្រវត្តិសាស្រ្ត តែមានភាពមិនច្បាស់លាស់ និងមិនត្រូវ បានបកស្រាយពីមុនមក។

## ២. សេចក្ដីសង្ខេបនៃសក្ខីកម្ម

សវនាការលើសំណុំរឿង ០០២/០២ដែលមានចំនួន២៧៤ថ្ងៃ អង្គជំនុំជម្រះបានស្ដាប់សក្ខីកម្ម សរុបចំនួន១៨៦នាក់ ដែលក្នុងនោះមានសាក្សីចំនួន១១៤នាក់ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន៦៤នាក់ និងអ្នកជំនាញចំនួន៨នាក់។[1]ពួកគេត្រូវបានហៅឱ្យផ្ដល់សក្ខីកម្មលើការជំនុំជម្រះមួយក្នុង ចំណោមការជំនុំជម្រះចំនួន ៦ដាច់ដោយឡែកពីគ្នា រួមមាន: ១)ការដ្ឋាននិងសហករណ៍ ២)មន្ទីរសន្តិសុខនិងការ សម្អាតផ្ទៃក្នុង ៣)ការប្រព្រឹត្តលើក្រុមគោលដៅ ៤)ការរៀបចំអាពាហ៍ពិពាហ៍ ៥)សភាវៈនៃជម្លោះ ប្រដាប់អាវុធ និង៦)តួនាទីរបស់ជនជាប់ចោទ។ ខាងក្រោមនេះ គឺជាទិដ្ឋភាពទូទៅ នៃភស្តុតាង សំខាន់ដែលបានបង្ហាញក្នុងការជំនុំជម្រះដោយសង្ខេបទៅតាមប្រភេទនីមួយៗ។ សម្រាប់សេចក្ដី សង្ខេបលម្អិតនៃភស្តុតាង ឬសាក្សីដែលបានលើកឡើងសូមពិនិត្យលើរបាយការណ៍ឃ្លាំមើលប្រចាំ សប្ដាហ៍របស់កម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម ចេញផ្សាយលេខទី១ ដល់លេខ ៨០។[2]

### ក. ការដ្ឋាននិងសហករណ៍

សំណុំរឿង ០០២/០១ ផ្ដោតលើបទពិសោធន៍នៃការជម្លៀសដោយបង្ខំលើប្រជាជន ក្នុងទីក្រុង នានាក្នុងប្រទេសកម្ពុជាក្នុងខែមេសា ឆ្នាំ ១៩៧៥ ខណៈដែលសំណុំរឿង ០០២/០២ បានបង្វែរការ
យកចិត្តទុកដាក់លើបទពិសោធន៍ជីវិតរស់នៅទីជនបទ និងពលកម្មហួសកម្លាំងក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះបានចាប់ផ្ដើមសវនាការលើភស្តុតាង ដោយស្ដាប់សក្ខីកម្មអស់ រយៈ ពេលជាង ៦ខែ ស្ដីពីសហករណ៍ត្រាំកក់ (ដែលគេ ស្គាល់ថាស្រុក១០៥ ស្ថិតនៅភូមិភាគនិរតី ក្រោម ប្រព័ន្ធរដ្ឋបាលរបបកម្ពុជាប្រជាធិបតេយ្យក្នុងខេត្តតាកែវនាពេលបច្ចុប្បន្ន)និងពលកម្មដោយបង្ខំនៅទំនប់ ១មករា ទំនប់ត្រពាំងថ្ម និងការដ្ឋានសាងសង់ ព្រលានយន្តហោះកំពង់ឆ្នាំង។ អ្នកដែលបាន ផ្ដល់សក្ខីកម្មក្នុងផ្នែកនេះ

---

[1] ការជំនុំជម្រះសំណុំរឿង ០០២/០២ ប្រើប្រាស់ពេល៥១ ថ្ងៃលើសសំណុំរឿង ០០២/០១ (កើនឡើង ១២២.៧៧%) ដែលក្នុងនោះបានស្ដាប់ សក្ខី កម្មបន្ថែមពីមនុស្ស ៩៤ រូប (ពោលគឺ ១៨៦រូប ធៀបនឹង ៩២រូប មានការកើនឡើងចំនួន ២០២%) ។ ការណ៍នេះមិនរាប់បញ្ចូលកំណើន ប្រសិទ្ធភាពនៃ អង្គជំនុំជម្រះសាលាដំបូង ដោយហេតុថាក្នុងសំណុំរឿង ០០២/០១ បានបញ្ចូលក្រុមមេធាវីការពារក្ដីទី ៣ រហូតដល់មរណភាពរបស់ អៀង សារី នៅខែមីនា ឆ្នាំ ២០១៣ ។ ហើយចំណុចទីពីរ សាក្សីមួយចំនួនដែលរួមមាន លោកឆាង យុ និងលោក វណ្ណថន តារា ពៅ ដែលបានផ្ដល់ភស្តុតាងក្នុងសំណុំរឿង ០០២/០១ មិនចាំបាច់បង្ហាញខ្លួនម្ដងទៀតនៅក្នុងសវនាការដំណាក់កាលទីពីរ ដែលជាមូលដ្ឋានគ្រឹះនៃសំណុំ រឿង ០០២/០២ ។

[2] របាយការណ៍តាមដានប្រចាំសប្ដាហ៍សម្រាប់សំណុំរឿង ០០១ ០០២/០១ និង ០០២/០២ អាចរកបាននៅលើគេហទំព័រ www.krtmonitor.org

បាននិយាយអំពីសាច់រឿងផ្សេងៗគ្នា ពីរឿងរ៉ាវលម្អិតតគខ្លឹមសារធ្វើការ ហួសម៉ោង ការលុបបំបាត់ចោល ពិធីបុណ្យព្រះពុទ្ធសាសនាយ៉ាងឆាប់រហ័ស ភាពតក់ស្លុតនៃការ បាត់ខ្លួនភ្លាមៗ ឬការស្លាប់របស់មិត្តភក្តិ សមាជិកគ្រួសារ និងអ្នកជិតខាងរបស់ពួកគេនៅទូទាំង សហករណ៍និងការដ្ឋានសាងសង់។ ផ្នែកដំបូងនៃ សវនាការនេះ បានរៀបរាប់លម្អិតអំពីបទ ពិសោធន៍ដែលពលរដ្ឋកម្ពុជាទូទៅ បានជួបប្រទះជារួម និងយ៉ាង ទូលំទូលាយក្រោមរបបកម្ពុជា ប្រជាធិបតេយ្យ។

ពេលបិទបញ្ចប់ការលើកទឡ្ហីករណ៍ការិយាល័យសហព្រះរាជអាជ្ញា (OCP) បានសង្កត់ធ្ងន់លើការ ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទចំពោះតួនាទីរបស់ពួកគេក្នុងការបង្កើត និងតម្រង់ គោលនយោបាយ "មហាលោតផ្លោះ" របស់បក្សកុម្មុយនិស្តកម្ពុជា (CPK) ដែលឈានទៅដល់ការ បង្កើត សហករណ៍និងការដ្ឋានសាងសង់។ ព្រះរាជអាជ្ញាបានអះអាងថាឧក្រិដ្ឋកម្មបែបទាសភាពនៅ បណ្តាទីតាំង ទាំងនេះគឺជា"ឧក្រិដ្ឋកម្មដែលប៉ះពាល់ដល់ប្រជាជនកម្ពុជាស្ទើរតែគ្រប់រូបដែលបានរស់នៅក្រោមរបប កម្ពុជាប្រជាធិបតេយ្យ"។ មេធាវីការពារក្តី លោកនួន ជា បានបដិសេធការចោទ ប្រកាន់ពីឧក្រិដ្ឋកម្មបែប ទាសភាពនៅការដ្ឋាននិងសហករណ៍ ដោយចាត់ទុកថាវាជា "ភាពល្ងង់ខ្លៅ នៃសង្គមនិយម" ។ មេធាវី ការពារលោក ខៀវ សំផន បានប្រកែកថា ការិយាល័យសហព្រះរាជ អាជ្ញា និងដើមបណ្តឹង រដ្ឋប្បវេណី ខកខានក្នុងការបង្កើតធាតុផ្សំបទល្មើសលើជនជាប់ចោទ ស្តីអំពី អំពើទាសភាពនៅការដ្ឋាននិង សហករណ៍។ គាត់ក៏បានសម្តែងការមិនយល់ស្របថាអំពើឧក្រិដ្ឋកម្ម បែបទាសភាពមិនបានបំពេញតាម លក្ខខំណ្ឌពីរដែលបានកំណត់ គឺការប្រើប្រាស់សិទ្ធិកាន់ កាប់ និង ការដាក់កំហិតឱ្យធ្វើពលកម្មដោយបង្ខំ។ ឆ្លើយតបនឹងបញ្ហានេះ ភាគីដើមបណ្តឹងរដ្ឋប្បវេណីបាន លើកឡើងពីទស្សនវិស័យរបស់ខ្លួនអំពីបទឧក្រិដ្ឋ នៃអំពើទាសភាពដោយលើកឡើង ពីនិយមន័យ របស់អង្គជំនុំជម្រះតុលាការកំ ពូល (SCC) ពីធាតុផ្សំ បទល្មើស នៃអំពើទាសភាព ហើយអះអាងថា សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញឱ្យឃើញពី ការគ្រប់គ្រងទាំងស្រុងរបស់របបកម្ពុជាប្រជាធិបតេយ្យ (CPK) លើប្រជាជនទាំងស្រុង។

## ខ. មន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង

ក្នុងចំណោមមន្ទីរសន្តិសុខទាំង ១១ ដែលមានរៀបរាប់ក្នុងដីកាដំណោះស្រា យនៃសំណុំរឿង ០០២ អង្គ ជំនុំជម្រះសាលាដំបូងបានជ្រើសរើសយកមន្ទីរសន្តិសុខចំនួន៤ ដើម្បីសាកល្បងជាផ្នែកមួយនៃ សំណុំរឿង០០២/០២ រួមមាន: ក្រាំងតាចាន់ ភ្នំក្រោល អូរកន្សែង និងមន្ទីរស ២១ (ដែលចុង ក្រោយត្រូវ បានលើកឡើងយ៉ាងទូលំទូលាយក្នុងសំណុំរឿង០០១)[3]ជនជាប់ចោទត្រូវបានចោទ ប្រកាន់នៅក្នុងដីកា

[3] មន្ទីរសន្តិសុខដែលមិនបានដាក់បញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ រួមមានមន្ទីរសន្តិសុខសង់ មន្ទីរសន្តិសុខកោះខ្យង មន្ទីរសន្តិសុខព្រៃដំរីស្រុត មន្ទីរសន្តិសុខវត្តគីរីរម្យ មន្ទីរសន្តិសុខភូមិភាគឧត្តរ មន្ទីរសន្តិសុខក្រូចឆ្មារ និងមន្ទីរសន្តិសុខវត្តធ្លក។

ដំណោះស្រាយលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាសភាពការសម្លាប់ រង្គាល ការឃុំឃាំង អំពើឃាតកម្ម ការធ្វើទុក្ខបុកម្នេញ ដោយនិន្នការនយោបាយនិងពូជសាសន៍ អំពើ ទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេង ទៀតតាមរយៈការអំពេ ីឃោរឃៅប្រឆាំងនឹងសេចក្តីថ្លៃថ្នូរ របស់មនុស្ស ការរំលោភសេពសន្ថវៈ ការរៀបការដោយបង្ខំ ការបាត់ខ្លួន ការរំលោភយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ នៅក្នុងមន្ទីរសន្តិសុខទាំង ៤នេះ ។ អ្នកដែលផ្តល់ សក្ខីកម្មក្នុងផ្នែកនេះរួមមានអតីតជនដែលជាប់ឃុំឃាំង សាច់ញាតិរបស់អតីតជនជាប់ឃុំ ឬអ្នក ដែលបានធ្វើការនៅមន្ទីរសន្តិសុខជាឆ្មាំ អ្នកថតរូបអ្នកកត់ត្រា ឬអ្នកសួរចម្លើយ។

មន្ទីរសន្តិសុខស ២១

មន្ទីរសន្តិសុខដែលត្រូវបានគេដឹងលឺច្រើនជាងគេក្នុងចំណោមមន្ទីរសន្តិសុខទាំងបួន ដែលត្រូវបានលើកយកមកពិចារណាចុងក្រោយគេនៅក្នុងសំណុំរឿង ០០២/០២ ។ មន្ទីរស ២១ ឬ មន្ទីរឃុំឃាំង ទួលស្លែង ស្ថិតនៅកណ្តាលក្រុងភ្នំពេញ ក្រោមការគ្រប់ គ្រងដោយលោក កាំង ហ្គេចអៀវ ហៅថា ឌុចចុងចោទតែមួយរូបគត់នៅក្នុងសំណុំរឿង ០០១ ។ ឌុច ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ អស់មួយជីវិតក្នុងតួនាទីជាមេគុក។[4] នៅពាក់កណ្តាលឆ្នាំ ២០១៦ ឌុចបានចេញពីមន្ទីរឃុំឃាំង នៅក្នុងខេត្តកណ្តាល ចំនួនជាង១២ថ្ងៃមកបង្ហាញខ្លួនជាសាក្សីក្នុងសំណុំរឿង ០០២/០២ លើ តួនាទីរបស់គាត់ជាមេគុក និងអំពីទំនាក់ទំនងដែលគាត់មានជាមួយ នួន ជា ប្រធានរបស់ គាត់នៅពេលនោះ។ បើទោះជា នួន ជា បានបដិសេធពីការទទួលខុសត្រូវចំពោះអ្វីដែលបានកើត ឡើងនៅមន្ទីរស ២១ ប៉ុន្តែឌុចបានសម្តែងការភ្ញាក់ផ្អើលចំពោះការបដិសេធនេះ ដោយបានផ្តល់នូវ ឧទាហរណ៍ជាក់លាក់នៅពេលដែលគាត់បានទទួលបញ្ជាពី «បងនួន» ដោយលើកឡើងថា "គ្រប់ កិច្ចការទាំងអស់មានការពាក់ព័ន្ធជាមួយ នួន ជា ផងដែរ "។

ជារួមមានសាក្សីចំនួន ១០រូប ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦រូបនិងអ្នកជំនាញ ១រូប ដែលបាន ផ្តល់សក្ខីកម្មនៅក្នុងករណីមន្ទីរស ២១ រួមមានលោក ជុំ ម៉ី ជនរងគ្រោះមន្ទីរឃុំឃាំងស ២១ ដែលនៅរស់រានមានជីវិតដែលជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបគត់ ដែលផ្តល់សក្ខីកម្មនៅខាងក្រៅ
សវនាការអំពីផលប៉ះពាល់លើជនរងគ្រោះ។ ខណៈដែលចំនួនសក្ខីកម្មពីអតីតកម្មករធ្វើការនៅ មន្ទីរសន្តិសុខ និងអតីតអ្នកជាប់ឃុំ នៅមន្ទីសន្តិសុខទាំងបី មានចំនួនស្មើរស្មើគ្នា ចំនួនអ្នករស់រាន មានជីវិតពីមន្ទីរ

4 ដំបូងឡើយ ឌុចត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ ៣៥ ឆ្នាំដោយកាត់បន្ថយរយៈពេលប្រាំឆ្នាំ ខណៈដែលគាត់ត្រូវបានឃុំឃាំង នៅក្នុងពន្ធនាគារអស់ពេល ៨ ឆ្នាំមុនការជំនុំជម្រះ ទោះបីជាយ៉ាងនេះក្តីបន្ទាប់ពីបណ្តឹងឧទ្ធរណ៍គាត់ត្រូវបានដាក់ឱ្យជាប់ពន្ធនាគារអស់មួយជីវិត។ សូមមើល "សេចក្តីវិនិច្ឆ័យ" របស់អង្គជំនុំជម្រះសាលាដំបូង, (ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១០), E188; និង "សាលដីកា" របស់អង្គជំនុំជម្រះតុលាការ កំពូលលើបណ្តឹងឧទ្ធរណ៍ (ថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២), F28 ។

ស ២១ មានកម្រិតទាបក្នុងការធ្វើជាសាក្សីលើផ្នែកនេះ។[5] សំណុំរឿង ០០១ ទទួ លបានការផ្ត ល់សក្ខីកម្មជាច្រើនពីអ្នកនៅរស់រានជីវិតនិងសាច់ញាតិ ខណៈដែលករណីស ២១ ក្នុងសំណុំរឿង ០០២/០២ ទទួលបានសក្ខីកម្មច្រើនពីអ្នកយាម អ្នកសួរចម្លើយ អ្នកថតរូប និងបុគ្គលិករដ្ឋបាល។ នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់សហព្រះរាជអាជ្ញាបានសំដៅម្តងហើយម្តង ទៀតថាមន្ទីរឃុំឃាំងស ២១ ជា "កន្លែងឧក្រិដ្ឋកម្មដ៏សំខាន់បំផុត" នៅក្នុងសំណុំរឿង ០០២/០២ ដោយលើកហេតុផលថា"អ្វីដែលបានកើតឡើងនោះគឺជាកត្តាកំណត់យ៉ាងច្បាស់លាស់អំពីការឃុំឃាំងនិងការកាត់ទោសដោយខុសច្បាប់និងក្រៅប្រព័ន្ធតុលាការ" ។[6]

## ការបោសសម្អាតផ្ទៃក្នុង

នៅដើមដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រទេសកម្ពុជាត្រូវបានបែងចែកជា ៦តំបន់ដែល ក្រោយ មកត្រូវបានពង្រីកដល់ ៧តំបន់នៅឆ្នាំ ១៩៧៧ នៅពេលដែលតំបន់ខាងជើង ត្រូវបានបែងចែក ទៅ ជាតំបន់ខាងជើងនិងតំបន់កណ្តាល។[7] ធាតុផ្សំសំខាន់នៃការជំទាស់របស់មេធាវីការពារក្តីឱ្យលោ ក នួន ជា គឺអាស្រ័យទៅលើការអះអាងថាបក្សពួកនិយមបានរីករាលដាលនៅក្នុងបក្សកុម្មុយនិស្ត
កម្ពុជា ហើយកងកម្លាំងរបស់មន្ទីរសន្តិសុខដែលមានមូលដ្ឋានក្នុងក្រុងភ្នំពេញ ដែលមានទាំងលោក នួន ជា ផងដែរមានអំណាចតិចតួច ឬដឹងអំពីអ្វីដែលបានកើតឡើងនៅតំបន់ខាងក្រៅនោះទេ។ អតីតកម្មាភិបាលចាស់ៗមួយចំនួនមកពីភូមិភាគបូព៌ា បានផ្តល់សក្ខីកម្មអំពីការបោសសម្អា តដែល បានកើតឡើងនៅទីនោះជាតួយ៉ាងដើមបណ្តឹងរដ្ឋប្បវេណីលោក ឈុន សាម៉ន បានកោះហៅ ទាហានមកពីតំបន់កណ្តាលនិងនិរតីដែលមកដល់ភូមិភាគបូព៌ាក្នុងឆ្នាំ ១៩៧៧ ឱ្យត្រលប់មកវិញ ហើយមានបំណងវាយឱ្យបែកនៅឆ្នាំ ១៩៧៨ ។ លោក មាស សឿន កូនប្រុសរបស់អតីតអនុ ប្រធានភូមិភាគបូព៌ាបានផ្តល់សក្ខីកម្មថាការបោសសម្អាតតំបន់បូព៌ាបានចាប់ផ្តើមនៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៧៨ បន្ទាប់ពីមានការប៉ុនប៉ងធ្វើ រដ្ឋប្រហារ ក្រោមការដឹកនាំរបស់លោក សៅ ភឹម លេខាធិការភូមិភាគបូព៌ា។អ្នកដែលធ្វើការនៅភូមិភាគបូព៌ាត្រូវបានចោទប្រកាន់ថាបានសហការជាមួយវៀតណាមហើយកម្មាភិបាលទាំងនោះត្រូវបានបញ្ជូនចេញជំនួសមកវិញដោយកម្មាភិបាល មក ពីភូមិភាគកណ្តាលរួមទាំងឪពុករបស់លោក មាស សឿន ផងដែរ ដែលគេហៅថា"បញ្ជូនទៅរៀន" ហើយគាត់មិនដែលឃើញឪពុករបស់គាត់ឬអ្នកដឹកនាំផ្សេងទៀតម្តងទៀតឡើយចាប់ពីពេលនោះមក។ គោលដៅចម្បងនៃការបោសសំអាតនៅភូមិភាគខាងជើងគឺទាហានមកពីកងពលធំ

---

5 សវនាការពិសេសស្តីពីផលប៉ះពាល់ល់ជនរងគ្រោះ ត្រូវបានរៀបចំដើម្បីស្តាប់សក្ខីកម្មពីដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំរូបផ្សេងទៀត ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ១១ និងថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៦ ។ នៅក្នុងសវនាការស្តីពីប៉ះពាល់ដល់ជនរងគ្រោះ មិនមានមន្ទីរសន្តិសុខផ្សេងទៀតណាត្រូវបានលើកយកមកនោះទេ។

6 អង្គជំនុំជម្រះសាលាដំបូង 'ប្រតិចារឹកនៃដំណើរការជំនុំជម្រះ (សាធារណៈ)' (ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១៧) E1 / 521.1, ទំព័រ ១០៩ ។

7 ក្រៅពីតំបន់ ឬភូមិភាគ ដែលត្រូវរាយការណ៍ដោយផ្ទាល់ទៅថ្នាក់មជ្ឈឹមនោះ របបកម្ពុជាប្រជាធិបតេយ្យក៏មាន តំបន់ស្វយ័តភាពចំនួនប្រាំផ្សេងទៀត (ក្នុងនោះពីរតំបន់ត្រូវបានច្របាច់បញ្ចូលគ្នាដើម្បីបង្កើតភូមិភាគឧត្តរថ្មីនៅឆ្នាំ ១៩៧៧) និងតំបន់ភ្នំពេញដែលឯករាជ្យពីតំបន់ណាៗទាំងអស់។ សម្រាប់ព័ត៌មានលម្អិត, សូមមើលសេចក្តីសន្និដ្ឋានបិទបញ្ចប់ សំណុំរឿង ០០២ ទំព័រ ២៣ វាក្យខណ្ឌ ៦៥។

៣១០ នៃ កងទ័ពបដិវត្តន៍កម្ពុជា **RAK**) ។ ក្នុងឆ្នាំ ១៩៧៧ កងកម្លាំងភូមិភាគនិរតីបានចូលភូមិភាគ ខាងជើង ហើយបានចាប់ខ្លួនកម្មាភិបាលរួមទាំងលេខាកងពលធំ ៣០១ លោកតា អឿនដែលត្រូវបាន ប្រកាន់ ថាបានគ្រោងធ្វើរដ្ឋប្រហារ។ អតីតកម្មាភិបាលភូមិភាគខាងជើង បានថាផ្តល់សក្ខីកម្មថាពួកគេត្រូវ បានបញ្ជូនទៅ "លត់ដំ" នៅឯការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ក្រោយពេលចាប់ ខ្លួន។ អ្នកផ្តល់សក្ខីកម្មខ្លះ ថាប្រពន្ធនិងកូនពួកកម្មាភិបាលដែលត្រូវចាប់ខ្លួន ក៏ត្រូវបានចាប់ខ្លួន ដែរ។

## គ. ការប្រព្រឹត្តលើក្រុមគោលដៅជាក់លាក់

អង្គជំនុំជម្រះសាលាដំបូង បានចោទប្រកាន់ជនជាប់ចោទថាបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ប្រឆាំងនឹងជនជាតិភាគតិចវៀតណាមនិងចាម។ ការចោទប្រកាន់ក្នុងសំណុំរឿង ០០២/០២ ដោយដាក់បញ្ចូលជនជាតិចាមនិងវៀតណាម គឺជាករណីទីមួយអំពីអំពេីប្រល័យពូជសាសន៍នៅអ.វ.ត.ក។ ប្រសិនបើ អ.វ.ត.ក ផ្តោលទោសពីបទប្រល័យពូជសាសន៍ក្នុងសំណុំរឿង ០០២/០២ វាគឺជាការ
វិវឌ្ឍន៍ដ៏រគួរឱ្យកត់សម្គាល់ក្នុងប្រវត្តិសាស្រ្ត។ មេធាវីការពារក្តីលោក វិចទ័រ កូប៉េ (Victor Koppe) បានស្នើសុំចៅក្រមពេលបិទបញ្ចប់ការផ្តល់ទឡ្ហីករណ៍ ឱ្យរក្សាភាពអព្យាក្រិត្យ មិនលំអៀង ដោយកត់សម្គាល់ថាវាអាចជា "ចេតនារបស់សាលាក្តី ក្នុងការបង្កើតកេរដំណែលនៃការកាត់ទោសរបប ប្រល័យពូជសាសន៍នៅកម្ពុជា" ។

ធាតុផ្សំនៃបទចោទដ៏សំខាន់មួយផ្សេងទៀតនៅក្នុងបរិបទសហសម័យកម្ពុជា គឺទីតាំងដែលរបប
កម្ពុជាប្រជាធិបតេយ្យអាចប្រើប្រាស់ ដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ប្រឆាំងជនជាតិភាគតិច រួមទាំងជនជាតិភាគតិចវៀតណាម ដោយមិនគិតពីជនជាតិខ្មែរភាគច្រើនដែលទទួលរងគ្រោះធ្ងន់ ធ្ងរដូចគ្នាផងនោះទេ។ ទោះបីជាការជជែកដេញដោលជាច្រើនមិនអាចបែងចែកភាពខុសគ្នាលើ
អត្ថន័យ រវាងឧក្រិដ្ឋកម្មដ៏សាហាវឃោរឃៅ ក៏ភារកិច្ចផ្លូវច្បាប់ដែលអង្គជំនុំជម្រះសាលាដំបូង ប្រឈម ក្នុងសំណុំរឿង ០០២/០២ គឺត្រូវចេញសេចក្តីសម្រេចថាតើក្រុមជនជាតិភាគតិចទាំងពីរ នេះ ត្រូវបានគេកំណត់គោលដៅក្នុង "ចេតនាបំផ្លាញ ទាំងស្រុងឬដោយអន្លើ នូវប្រជាជាតិជនជាតិ ពូជសាសន៍ឬក្រុមសាសនាក្នុងន័យបែបនេះ" ស្របតាមការកំណត់និ យមន័យ អំពើ ប្រល័យ ពូជសាសន៍ ដូចមានចែងក្នុងអនុសញ្ញាប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨។[8]ការិយាល័យសហ ព្រះរាជអាជ្ញាបានរំឮកម្តងហើយម្តងទៀតដល់ អង្គជំនុំជម្រះ សាលាដំបូងទាំងនៅក្នុង សវនាការ និង បិទបញ្ចប់សេចក្តីសន្និដ្ឋានដែលថាអំពើប្រល័យពូជសាសន៍ ពុំមានកម្រិតអប្បបរមា សម្រាប់ចំនួន មនុស្ស ដែលត្រូវបានសំលាប់ ដែលខុសគ្នាពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិការសម្លាប់រង្គាលដែល តម្រូវឱ្យមានការសម្លាប់នៅក្នុងទ្រង់ទ្រាយធំ។

[8] មហាសន្និបាតអង្គការសហប្រជាជាតិ "អនុសញ្ញាស្តីពីការបង្ការនិងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍" (អនុម័តនៅថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ១៩៤៨) លេខ ១០២១ មាត្រាទី ២ ។

ការកំណត់ក្រុមគោលដៅជនជាតិចាម

ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ មកលើជនជាតិចាមនៅក្នុងប្រទេសកម្ពុជា ដូចបានលាតបង្ហាញនៅក្នុងដីកាដំណោះស្រាយលើព្រឹត្តិការណ៍ដែលបានកើតឡើងនៅទីតាំងឧក្រិដ្ឋកម្មដូនតាជនជាតិចាមនៅក្នុងខេត្តកំពង់ចាម  នៃភូមិភាគកណ្ដាលនិងនិរតីនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះសាលាដំបូងបានស្ដាប់ចម្លើយកសិណពីសាក្សីចំនួន ១៣ រូប ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន  ៥រូប (ពីរនាក់បានផ្ដល់សក្ខីកម្មនៅក្ន ុងសវនាការស្ដីពីផលប៉ះពាល់ដល់  ជនរងគ្រោះ) និងអ្នកជំនាញ យូសា អូសស្មាន់ (Ysa Osman) នៅក្នុងសវនាការដោយចំពោះ។ ដោយ សារជនជាតិចាមជាអត្តសញ្ញាណនៃក្រុមជនជាតិភាគតិចនិងក្រុមសាសនា  ជនជាប់ចោទមិនត្រឹម  តែត្រូវបានចោទប្រកាន់  ពីបទប្រល័យពូជសាសន៍ក្នុងចេតនាកម្ទេចចោលក្រុមនេះតែប៉ុណ្ណោះទេ  តែរួមនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាំងផ្នែកពូជសាសន៍និងសាសនា។ការិយាល័យសហព្រះរាជអាជ្ញា  បានលើកម្ដងហើយម្ដងទៀតថាការរកឃើញនៃអំពើប្រល័យពូជសាសន៍ មិនពឹងផ្អែក លើ ចំនួនមនុស្សដែលត្រូវបានគេសម្លាប់នោះទេប៉ុន្តែចេតនារបស់បក្សកុម្មុយនីសកម្ពុជាក្នុងការ  កម្ទេច  ធាតុផ្សំនានា  ជាពិសេសការអនុវត្តផ្នែកសាសនា ដែលធ្វើឱ្យជនជាតិចាមក្លាយជាក្រុមមួយខុសគេ។ ក្នុងន័យនេះ សហព្រះរាជាជ្ញា បានពឹងផ្អែកលើសក្ខីកម្មដែលបានស្ដាប់លឺក្នុងអង្គសវនាការជុំវិញ ការបដិសេធ របស់ខ្មែរក្រហម លើសិទ្ធិសាសនារបស់ជនជាតិចាម  ការបង្ខំអោយបរិភោគសាច់ជ្រូក  ការបង្ខំឱ្យនារីកាត់សក់ខ្លីនិងការដុតគម្ពីរបរិសុទ្ធ។  ទាំងការិយាល័យសហព្រះរាជអាជ្ញា និងសហមេ  ធាវីនាំមុខដើមបណ្ដឹងរដ្ឋប្ប  វេណី  បានដាក់ភ័ស្ដុតាងដើម្បីបង្កើតឱ្យមានការបកស្រាយយ៉ាង
ច្បាស់លាស់អំពីចេតនាប្រល័យពូជសាសន៍របស់បក្សកុម្មុយនីស្តកម្ពុជាដែលថាៈ  អំពើបះបោរនៅ  ក្នុងឆ្នាំ ១៩៧៥ របស់កសិករជនជាតិចាមនិងអ្នកនេសាទប្រឆាំង នឹងការដាក់កំហិតខាងសាសនា របស់របបថ្មីនិងការបង្ខិតបង្ខំ  នាំឱ្យមានការបង្ក្រាបដោយហឹង្សា  ឃាតកម្មនិងការជម្លៀសដោយបង្ខំ  ទៅកាន់តំបន់រហោស្ថានដែលពីមុនសម្បូរដោយជនជាតិចាមរស់នៅ។ សាក្សីនិងដើមបណ្ដឹងរដ្ឋប្ប វេណី បានផ្ដល់ឈ្មោះនិងទីតាំងនៃបណ្ដាកន្លែងនិរទេសនិងសម្លាប់រង្គាលទាំងនេះ ដោយសង្កត់ធ្ងន់ ជាពិសេសទៅលើការសម្លាប់នៅវត្តរវត្តអូរត្រកួនក្នុងស្រុកកងមាស ភូមិភាគកណ្ដាលនិងភូមិទ្រា ស្រុកក្រូចឆ្មារ ភូមិភាគបូព៌ា។

ក្រុមមេធាវីការពារក្ដី លោកខៀវ សំផន មិនបានបដិសេធអំពីភាពរងគ្រោះរបស់ជនជាតិចាមក្នុង របបកម្ពុជាប្រជាធិបតេយ្យទេ ប៉ុន្តែគាត់មិនទទួ  លយកការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់កូន   ក្ដីខ្លួនចំពោះទុក្ខសោកនេះឡើយ។ ក្រុមមេធាវីការពារនេ ៖  ក៏បានលើកឡើងផងដែរថា  ការិយាល័យ  សហព្រះរាជាអាជ្ញា ពឹងផ្អែកយ៉ាង ខ្លាំងទៅ លើសេចក្ដីថ្លែងរបស់សាក្សី  និងការសម្ភាសន៍ប្រភព បន្ទាប់បន្សំដូចជាករណីរបស់លោក  យូសា  អូសស្មាន់  (Ysa  Osman)  និងលោក  បិន  គៀណាន់  (Ben  Kiernan)ជាជាងឯកសារ

ដែលផ្តល់ដោយបក្សកុម្មុយនីស្តកម្ពុជា ជាភស្តុតាងអំពីគោលនយោបាយ ប្រល័យពូជសាសន៍របស់មន្ទីរសន្តិសុខ កម្ពុជាប្រជាធិបតេយ្យ ។ មេធាវីការពារក្តីបានកត់សម្គាល់ថា ជនល្មើសនៅថ្នាក់ទាបជាច្រើនដែលបានផ្តល់សក្ខីកម្ម មិនដែលបានរៀបរាប់ពី ការបញ្ជារបស់នរណា ម្នាក់ហួសពីថ្នាក់លើរបស់ខ្លួន ក្នុងការប្រព្រឹត្តប្រឆាំងនឹងជនជាតិចាមទេ។ មេធាវីការពារក្តីលោកនួន ជាបានទាញភ្ជាប់បន្ថែមទៀតថា ការិយាល័យសហព្រះរាជអាជ្ញា ខកខានក្នុងការផ្តល់ ភស្តុតាង គ្រប់គ្រាន់ពាក់ព័ន្ធនឹងបទពិ សោធន៍នេះជាមួយអត្តសញ្ញាណរបស់ជនជាតិចាម។ ក្រុមមេធាវីការពារ ក្តីឱ្យ លោកនួន ជា បានលើកឡើងថា គោលនយោបាយរបស់ បក្សកុម្មុយនីស្តកម្ពុជា គឺផ្តល់ សមភាព ដោយជំទាស់ថាការបែ ងចែកទីតាំងក្នុងមូលដ្ឋានដូចជាសហករណ៍និងផ្ទះបាយ ឬ មណ្ឌល សន្តិសុខ គឺអនុវត្តដូចគ្នាលើគ្រប់ជនជាតិ ឬសាសនា ដោយមិនផ្តោតលើជនជាតិចាមជាពិសេស នោះទេ។ មេធាវីការពារក្តី លោកនួន ជា ក៏បានលើកឡើងអំពីក្តីកង្វល់ផ្នែកសន្តិសុខលើការបះបោរ របស់ជនជាតិចាម ថាជាមូលហេតុនៃការបង្ក្រាបជាជាងអត្តសញ្ញាណរបស់ពួកគេ។ ទោះបីជា យ៉ាងណាក៏ដោយ ជាការឆ្លើយតបសហព្រះរាជអាជ្ញាអន្តរជាតិ បានចង្អុលបង្ហា ញថាចេតនាគិតគូរ ពីសន្តិសុខជាតិ មិនអាចផ្លាស់ប្តូរគោលបំណងដោយគ្រាន់សំដៅលើក្រុមនេះ តាមរយៈអ្វីដែលគាត់ បានអះអាងថាជាអំពើប្រល័យពូជសាសន៍។ ៩

ការកំណត់មុខសញ្ញាជនជាតិភាគតិចវៀតណាម

លោក នួន ជា និង លោកខៀវ សំផន ក៏ត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ប្រឆាំងនឹង ជនជាតិវៀតណាមនៅខេត្តព្រៃវែងនិងស្វាយរៀង នៅភូមិភាគបូព៌ានៃរបបកម្ពុជាប្រជាធិបតេយ្យផងដែរ។ ជារួមអង្គជំនុំជម្រះសាលាដំបូងបានស្តាប់ចម្លើយពី សាក្សីចំនួន១៣រូប ដើមបណ្តឹង រដ្ឋប្បវេណីចំនួន៧រូប(បីរូបបានចូលរួមផ្តល់សក្ខីកម្មនៅក្នុងសវនាការស្តីពីផលប៉ះពាល់ដល់ជនរងគ្រោះ) និងអ្នកជំនាញលោកវេជ្ជបណ្ឌិតហ៊ីនតុន ក្នុងសវនាការផ្នែកនេះ។ សាក្សីជាច្រើនបានផ្តល់ សក្ខីកម្មថាក្រុមគ្រួសារជនជាតិវៀតណាម ត្រូវបានគេកំណត់គោលដៅផ្អែកលើសាច់ឈាមខាង ម្តាយ ពោលគឺការសម្លាប់កូនៗរបស់ស្ត្រីជនជាតិវៀតណាមទាំងនោះ ដើម្បីបំបាត់ខ្សែលោហិត តែម្តង។ ការិយាល័យសហព្រះរាជអាជ្ញា បានលើកឡើងថាមានការបញ្ជាក់យ៉ាងច្បាស់នៅក្នុង គោលនយោបាយរបស់ បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកំចាត់ចោលជនជាតិវៀតណាមទាំងអស់ ចេញពីប្រទេសកម្ពុជា ដំបូងឡើយតាមរយៈការបង្ខំពួកគេឱ្យត្រឡប់ទៅប្រទេសវៀតណាមវិញ។ ជាមួយនឹងការយល់ស្របដែលថាការនិរទេសខ្លួនមិនមែនជាសកម្មភាពមួយក្នុងចំណោមសកម្មភាពទាំង៥ ដែលមានក្នុងមាត្រា ២នៃអនុសញ្ញាអំពើប្រល័យពូជសាសន៍នោះ សហព្រះរាជអាជ្ញា

---

[9] សហព្រះរាជអាជ្ញាអន្តរជាតិ បានសំដៅសាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់ *ICTY Stakić* ដែលចែងថា "នៅក្នុងបទប្រល័យពូជសាសន៍ ហេតុផលដែលជនជាប់ចោទ ព្យាយាមបំផ្លាញក្រុមជនរងគ្រោះពុំមានជាប់ពាក់ព័ន្ធនឹងកំហុសទេ" ។ សូមមើល សេចក្តីវិនិច្ឆ័យរបស់, ព្រះរាជអាជ្ញា ធៀបនឹងលោក*Stakić* (IT-97-24-A) អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់ ICTY ថ្ងៃទី ២២ ខែមីនាឆ្នាំ ២០០៦ ទំព័រ ១៨ ជំពូក ៥៥។

អន្តរជាតិ គូមជៀន (Koumjian) ជំទាស់ថានេះបង្ហាញពី ចេតនាក្នុងការកម្ទេចក្រុមនេះទាំងមូល ឬដោយអន្លើ។

ក្នុងសវនាការនោះ មេធាវីការពារក្តីលោ កនួន ជាបានលើកឡើងថា យើងពុំអាចវាស់វែងចំនួន ប្រជាជនវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជានៅមុនពេល អំឡុងពេល ឬភ្លាមៗក្រោយ របបកម្ពុជាប្រជាធិបតេយ្យនោះទេដោយសារកង្វះខាតព័ត៌មានប្រជាសាស្ត្រនៅគ្រានោះ។ មេធាវី លោកនួន ជាបានបន្តលើកឡើងទៀតថាការធ្វើទុក្ខបុកម្នេញឬការរើសអើងប្រឆាំងនឹងក្រុមណាមួយ គឺផ្ទុយពីគោលនយោបាយសមភាពរបស់ បក្សកុម្មុយនីស្តកម្ពុជា ។ គាត់ក៏បានអះអាងផងដែររបប កម្ពុជាប្រជាធិបតេយ្យ ចង់បង្កើនចំនួនប្រជាជននិងលើកទឹកចិត្តឱ្យប្រជាជនមានកូនច្រើន សូមមើល ផ្នែកទី ២.ឃ ខាងក្រោម) ដូចនេះវាមិនសមប្រកបទេដែលរបបនេះ ត្រូវសម្លាប់ ប្រជាជនមួយ ផ្នែក ធំនោះ។ នៅពេលទាញសេចក្តីសន្និដ្ឋានបិទបញ្ចប់ លោកខៀវ សំផនបានប្រើប្រាស់ឱកាសនោះ (ជាព្រឹត្តិការណ៍ដ៏កម្រមួយក្នុងរយៈពេលប៉ុន្មានឆ្នាំនៃការជំនុំជម្រះ)ដើម្បីអានសេចក្តីថ្លែងការណ៍ ដែលមានត្រៀមស្រេច ដែលដាក់ចំណងជើងការចោទប្រកាន់ពីរបបប្រល័យពូជសាសន៍ថា "ជារឿង គួរឱ្យអាម៉ាសនិងមិនសមនឹងកើតមានឡើង" ដោយបង្ហាញទស្សនៈរបស់គាត់ថាប្រទេសវៀតណាម "បានប្រមូលផលពីការពង្រីកមហិច្ឆតារបស់ខ្លួន"ដោយធ្វើការឈ្លានពានរបបកម្ពុជាប្រជាធិបតេយ្យនៅដើមខែមករា ឆ្នាំ១៩៧៩ ។ ក្រុមមេធាវីការពារក្តីភាគច្រើនបានអះអាងថា "សត្រូវជនជាតិវៀត ណាម" ដែលមាននៅក្នុងឯកសាររបស់បក្សកុម្មុយនិស្តកម្ពុជា ដូចជាឯកសារពីមន្ទីរសន្តិ សុខស ២១ គឺសំដៅទៅលើភ្នាក់ងារយោធាវៀតណាមហើយថាបក្សកុម្មុយនិស្តកម្ពុជា មិនដែលកំណត់មុខសញ្ញា ដាក់ទោសលើជនស៊ីវិលនោះទេ។ ឆ្លើយតបទៅនឹងការជំទាស់នេះ សហព្រះរាជអាជ្ញាលោក Koumjian បានពណ៌នាថានេះជា "រឿងធម្មតា" នៃអំពើប្រល័យពូជសាសន៍ដែលអាជ្ញាធរក្រោយមក នឹងស្វែងរកភាពស្របច្បាប់នៃសកម្ម ភាពរបស់ខ្លួនដោយនិយាយថាគោលដៅរបស់ខ្លួនគឺជាការគំ រាមកំហែងដែលមានស្រាប់។

ការដាក់គោលដៅទៅលើអតីតយោធា និងមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ

ក្រៅពីបទចោទប្រកាន់អំពីអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មផ្សេងទៀតដែលប្រព្រឹត្តឡើង ប្រឆាំងនឹងក្រុមជនជាតិភាគតិចពីរដែលបានពិភាក្សាខាងលើ អង្គជំនុំជម្រះសាលាដំបូងក៏បានធ្វើ ការចោទប្រកាន់លើបទឧក្រិដ្ឋទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹ ងមនុស្សជាតិលើហេតុផល នយោ បាយរបស់អតីតទាហាននិងមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ ដែលត្រូវបានគេស្គាល់ផងដែរថាជា របប លន់ នល់នៅទីតាំងឧក្រិដ្ឋកម្មចំនួន ៤ កន្លែងរួមមាន: សហករណ៍ត្រាំកក់ ទំនប់ ១ មករា និងមន្ទីរសន្តិសុខស ២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ ក្នុងពេលទាញសេចក្តីសន្និដ្ឋានបញ្ចប់ លោកស្រី Anta Guissé មេធាវីអន្តរជាតិរបស់ លោកខៀវ សំផន បានលើកហេតុផលថា ការពិភាក្សារបស់ ការិយាល័យសហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខ

តំណាងដើមបណ្ដឹង រដ្ឋប្បវេណី លើការប្រព្រឹត្តចំពោះអតីតទាហាននិងមន្ត្រីនៃ របបលន់ នល់ គឺមិនសមស្រប ដោយផ្ដោតលក្ខណៈទូទាំងប្រទេស ជាជាងវិសាលភាពដ៏តូចចង្អៀតនេះ។ ក្រុមមេធាវីការពារក្ដីទាំងពីរ បានទាញការចាប់អារម្មណ៍លើសាលដីកាបណ្ដឹងឧទ្ធរណ៍របស់ អង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង ០០២/០១ ឱ្យច្រានចោលការផ្ដន្ទាទោសលើជនជាប់ចោទពីបទមនុស្សឃាត និងការសម្លាប់រង្គាលអតីតទាហានលន់ នល់ នៅទួលពោធិ៍ជ្រៃក្នុងខេត្តពោធិ៍សាត់ក្នុងឆ្នាំ១៩៧៥។ នៅក្នុងសាលដីកានោះ អង្គជំនុំជម្រះតុលាការកំពូល បានរកឃើញថាទោះបីជាការសម្លាប់បែបនេះហាក់ ដូចជាបានកើតឡើងក្ដី ក៏ពួកគេមិនអាចទាញភ្ជាប់ទៅនឹងគោលបំណងទូទៅនៃសហឧក្រិដ្ឋកម្មរួម ដែលត្រូវដាក់បញ្ចូលសហជនជាប់ចោទនោះទេ។ មេធាវីការពារក្ដីបានអះអាងថា ការរកឃើញនេះ អាចត្រូវបានអនុវត្តចំពោះកន្លែងឧក្រិដ្ឋកម្មដទៃទៀតដែលគ្របដណ្ដប់ក្នុងសំណុំរឿង ០០២/០២ ជា តួយ៉ាងមេធាវីការពារក្ដីលោកនួន ជា បញ្ជាក់ថាការផ្ដល់សក្ខីកម្មរបស់អតីត កម្មាភិបាលស្រុក ត្រាំកក់លោកពេជ្រ ជឹម ជាការដោះសារក្រោយពីការអះអាងរបស់គាត់ថា ភ្លាមៗក្រោយការដួលរលំ របស់ទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ ១៩៧៥ មន្ត្រី បក្សកុ ម្មុយនីស្តកម្ពុជា ត្រូវបានគេប្រាប់មិនឱ្យ កំណត់គោលដៅទៅ លើអតីតទាហាននៃសាធារណរដ្ឋខ្មែររហូតដល់ថ្នាក់វរសេនីយឯកឡើងទៅ។ ដោយសារសំណុំរឿង ០០២/០២ មានវិសាលភាពបណ្ដោះអាសន្នគ្របដណ្ដប់ពេញ មួយរបបខ្មែរ ក្រហមចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ ១៩៧៩ ដែលខុសពីការ ជំនុំជម្រះលើកដំបូងដែលផ្ដោតតែពីខែមេសា ឆ្នាំ ១៩៧៥ ដល់ខែធ្នូ ឆ្នាំ ១៩៧៧ អង្គជំនុំជម្រះ សាលាដំបូងនឹងអាចប្រើប្រាស់ឡើងវិញនូវការរកឃើញមួយចំនួនពីមុន និងភស្តុតាង ដើម្បីទទួល បានភាពលម្អិតកាន់តែច្រើនជាមួយនឹងបរិបទបន្ថែមទៀតលើហេតុផលនិងផលវិបាកនៃការគោលដៅចោទប្រកាន់ណាមួយ។

## ឃ. ការកំណត់នៃការរៀបអាពាហ៍ពិពាហ៍

+ជនជាប់ចោទទាំងពីរត្រូវបានចោទប្រកាន់លើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀតតាមរយៈការចាប់រៀបការដោយបង្ខំ និងការរំលោភក្នុងការរៀបការនោះ។[10] មនុស្សចំនួន ១៦ នាក់ត្រូវបានអញ្ជើញឱ្យផ្ដល់សក្ខីកម្មជាពិសេសអំពីការដាក់ បទកំណត់នៃ អាពាហ៍ពិពាហ៍ ទោះបីវាជាអ្វីមួយដែលប៉ះពាល់ដល់ជីវិតរបស់ មនុស្សជាច្រើនក្នុង សម័យកម្ពុជា ប្រជាធិបតេយ្យ ហើយជារឿយៗត្រូវបានលើកឡើងនៅក្នុងផ្នែកផ្សេងទៀត។ ការផ្ដល់សក្ខីកម្មរបស់ ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងផ្នែកនេះមានការខ្វះខាតខ្លាំង ដោយមានសាក្សីតែពីរនាក់និងសាក្សី ជំនាញពីរនាក់ក្នុងចំណោមមនុស្ស ១៦នាក់ ដែលបានបង្ហាញខ្លួន។ វាគឺជាផ្នែកតែមួយ គត់ដែល មានការផ្ដល់សក្ខីកម្មពីស្ត្រីច្រើនជាងបុរស។

---

[10] ដីកាដំណោះស្រាយលើសំណុំរឿង០០២ ទំព័រ ៣៥៤-៣៥៥ កថាខណ្ឌ ១៤៤១-១៤៤៧។

ភាគច្រើននៃអ្នកដែលបានផ្តល់សក្ខីកម្មនៅក្នុងផ្នែកនេះ បាននិយាយថាពួកគេទទួលបានការជូន ដំណឹងជាមុន តិចតួចណាស់អំពីអាពាហ៍ពិពាហ៍របស់ពួកគេក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយ ភាគច្រើនសម្តែងនូវក្តីទុក្ខព្រួយដែលឪពុកម្តាយរបស់ពួកគេបានចូលរួម ឬសូម្បីតែដឹងអំពី អាពាហ៍ ពិពាហ៍ កូនរបស់ខ្លួនដោយលើកឡើងថា "ឪពុកម្តាយរបស់ខ្ញុំហត់ នឿយណាស់ទម្រាំចិញ្ចឹម ខ្ញុំបានធំ"។ ហើយនៅពេលដែលខ្ញុំត្រូវរៀបការ តើពួកគាត់មិនអាចដឹងអំពីរឿង នេះយ៉ាងដូចម្តេច នឹងកើត? "។ ភាគច្រើនពួកគេរៀបការជាក្រុម ចាប់ពី ២ទៅ ៥០គូ ហើយពួកគេមិនបានស្គាល់ដៃ គូ របស់ខ្លួនមុនពេលពិធីរៀបការនោះទេ។ អ្នកទាំងនោះភាគច្រើន លើកឡើងថាពួកគេមានអារម្មណ៍ ឬត្រូវបានគេបង្ខំឱ្យរួមរស់ជាមួយគ្នានារាត្រីអាពាហ៍ពិពាហ៍របស់ខ្លួន។ សាក្សី 2-TCW-1037 បាន
ផ្តល់សក្ខីភាពថាអ្នកដែលលែងលះគ្នានឹងត្រូវគេនាំយកទៅសម្លាប់។ស្ត្រីខ្លះបានរៀបរាប់ថាខ្លួនត្រូវ បានស្វាមីថ្មីរបស់ខ្លួនចាប់រំលោភ ក្នុងនោះមានស្ត្រីម្នាក់បានប្រាប់អំពីសាច់រឿងដ៏គ្រាំគ្រាក្នុងបេះដូង ដែលនាងត្រូវបានចាប់រំលោភដោយមេបញ្ជាការយោធាជា«ការព្រមាន» ដែលនាងមិនព្រមចុះ ដំណេកជាមួយគូរៀបការថ្មីរបស់នាង។ស្ត្រីជាច្រើនក៏បាននិយាយផងដែរអំពីការមានផ្ទៃពោះក្រោយពេលរៀបការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ឬអំពើហិង្សាក្នុងគ្រួសារដែលពួកគេបាន ជួបប្រទះអស់រយៈកាលជាច្រើនឆ្នាំ ចាប់តាំងពីរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកស្រី ស៊ូ សុធារី ជាស្ត្រីប្តូរយេនឌ័រ បានថ្លែងពីការឈឺចាប់ដែលគាត់ត្រូវបានបង្ខំឱ្យរៀបការ ជាមួយស្ត្រីម្នាក់ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យហើយនិយាយថាគាត់បានឮអំពីពលរដ្ឋខ្មែរ ដែលប្តូរយេនឌ័រ ផ្សេង ទៀតដែលធ្វើអត្តឃាតក្នុងអំឡុងពេលរបបនេះ ជាជាងបង្ខំចិត្តរៀបការជាមួយអ្នកផ្សេងទៀតដែល ខ្លួនមិនបានជ្រើសរើស។

ក្រុមមេធាវីការពារក្តីទាំងពីមិនបានជំទាស់ទេថាគណបក្សកុម្មុយនិស្តកម្ពុជាមាន គោលនយោបាយគ្រប់គ្រងលើការរៀបអាពាហ៍ពិពាហ៍ ទោះជាយ៉ាងណា ភាគីទាំងពីរជំទាស់ថាគោលនយោបាយនេះ មិនសមជាបទឧក្រិដ្ឋ។ មេធាវីការពារក្តីលោកនួន ជាបានលើកឡើងថា បក្សកុម្មុយនីសកម្ពុជាមាន សិទ្ធបង្កើតគោលនយោបាយស្តីពីអាពាហ៍ពិពាហ៍ដើម្បីបង្កើនចំនួនប្រជាជនហើយថាគោលនយោបាយនេះ មិនជាប់ពាក់ព័ន្ធនិងកូនក្តីរបស់ខ្លួនទេ។ ផ្ទុយទៅវិញ ក្រុមមេធាវីការពារក្តីលោកខៀវ សំផនបានផ្តោតលើការពិតដែលថាគ្រប់ទម្រង់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនគួរត្រូវបាន ចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេនៅឆ្នាំ ១៩៧៥ ។ ក្រុមមេធាវីការពារក្តីទាំងពីរ បានចង្អុលបង្ហាញអំពីប្រពៃណីនៃអាពាហ៍ពិពាហ៍ដែលរៀបចំដោយគ្រួសារ ដែលមិនត្រូវបានចាត់ ទុកជាបទឧក្រិដ្ឋនៅក្នុងប្រទេសណាមួយនោះទេដោយបានប្រៀបធៀបទៅនឹងអាពាហ៍ពិពាហ៍ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ មេធាវីការពារក្តីលោកនួន ជា បានសង្កត់ធ្ងន់ជាពិសេសលើ "គោលការណ៍សីលធម៌បដិវត្តន៍ទី ៦" របស់ បក្សកុម្មុយនីសកម្ពុជា ដែលគ្រប់គ្រងលើទំនាក់ ទំនងរវាងបុរសនិងស្ត្រី ជាការហាមឃាត់យ៉ាងច្បាស់នៃអំ ពើរំលោភសេពសន្ថវៈ។ សាក្សីជំនាញ លោកស្រីKasumi Nakagawa បានកត់សម្គាល់ថាគោលការណ៍ នេះផ្តល់

ភាពស្របច្បាប់លើ អំពើរំលោភសេពសន្ថវៈ ក្នុងការរៀបការដោយបង្ខំ ហើយការព្រមព្រៀងរបស់ភាគីនៃគូអាពាហ៍ ពិពាហ៍ នោះមិនត្រូវបានផ្តល់ដោយសេរីទេក្នុងករណីជាច្រើន។

## ង. លក្ខណៈនៃទំនាស់ប្រដាប់អាវុធ

មេធាវីការពារក្តីរបស់លោកនួន ជា បានទាញទឡ្ហីករណ៍សំខាន់ៗពីរគឺការបែកបាក់ផ្ទៃក្នុងរបស់ បក្សកុម្មុយនីសកម្ពុជា ដែលកាត់បន្ថយការប្រើប្រាស់អំណាចរបស់ថ្នាក់មជ្ឈឹម និងការគម្រាមកំហែង ដែលរបបកម្ពុជាប្រជាធិបតេយ្យកំពុងប្រឈមមុខនឹងជម្លោះប្រដាប់អាវុធជាមួយវៀតណាម។ ចំនុច ទីពីរនេះ ត្រូវបានគេបែងចែកនៅក្នុងអនុផ្នែកជាក់លាក់ក្នុងដំណើរការកាត់ក្តី ដែលត្រូវបានគេសំដៅ ទៅល"លក្ខណៈនៃជម្លោះប្រដាប់អាវុធ"។ ក្នុងអំឡុងពេលសវនាការបឋមនៃសំណុំរឿង ០០២/០២ មេធាវីការពារក្តីរបស់ លោក នួន ជា បានលើកឡើងថាផ្នែកនេះគួរតែជាសវនាការលើកដំបូង សម្រាប់ជំនុំជម្រះ នេះបើតាមទស្សនៈរបស់ក្រុមខ្លួន ដោយសារតែយើងមិនអាចវិភាគ ព្រឹត្តិការណ៍ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានទេ បើគ្មានបរិបទនេះ។ ទឡ្ហីករណ៍ដែ លថាកម្ពុជាប្រជា ធិបតេយ្យ ទទួលរងការវាយប្រហារទាំងខាងក្នុង និងក្រៅខណៈពេលដែលកំពុងជាប់សង្គ្រាមជាមួយ ប្រទេសវៀតណាម ត្រូវបានប្រើក្នុងការកាត់ទោសដើម្បីបង្ហាញពីភាពត្រឹមត្រូវនៃគោលនយោបាយ សន្តិសុខជាតិនិងការពារជាតិ ក៏ដូចជាគោលនយោបាយដែលសំដៅលើជនជាតិវៀតណាម។ ការឆ្លើយតបរបស់ការិយាល័យសហព្រះរាជអាជ្ញាចំពោះអំ ណះអំណាងទាំងនេះគឺថាពេលដែល រដ្ឋមួយប្រកាសអាសន្នឬជាប់សង្គ្រាម មិនអាចផ្តល់យុត្តិធម៌ដល់ការសម្លាប់ក្រៅប្រព័ន្ធតុលាការ ឬ ការរំលោភសិទ្ធិមនុស្សផ្សេងទៀតដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទទាំងពីរនាក់ក្នុងបទ សហឧក្រិដ្ឋកម្មរួមគ្នានោះទេ។ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មពីសាក្សី ៦ នាក់និងអ្នកជំនាញ ១នាក់នៅក្នុងផ្នែកនេះ។

## ច. តួនាទីរបស់ជនជាប់ចោទ

ពេលទាញសេចក្តីសន្និដ្ឋានបិទបញ្ចប់ក្រុមមេធាវីការពារក្តីទាំងពីរបានសង្កត់ធ្ងន់ថាវាគឺជាកាតព្វកិច្ច របស់ក្រុមព្រះរាជអាជ្ញា ដែលមិនមែនជាតួនាទីរបស់មេធាវីការពារក្តី ដើម្បីបញ្ជាក់ពីការទទួលខុស ត្រូវខាងព្រហ្មទណ្ឌ ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងសវនាការនោះទេ។ ជនជាប់ ចោទទាំងពីរនាក់បានជំទាស់ថា គាត់មិនបានកាន់កាប់មុខតំណែងកំពូលក្នុងបក្សកុម្មុយនិស្តកម្ពុជា នួន ជា ជាអនុលេខាបក្សនិងខៀវ សំផន ជាប្រមុខរដ្ឋ។ ទោះបីជាយ៉ាងណាក៏ដោ យ ជនទាំង ពីរនាក់បានជំទាស់ថាពួកគេអាចត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មភាគច្រើន ដែលត្រូវបានចោទ ប្រកាន់នោះទេ។ នៅពេលថ្លែងបិទបញ្ចប់ សហព្រះរាជអាជ្ញាអន្តរជាតិលោក Nicholas Koumjian បានលើកឡើងម្តងហើយម្តងទៀតថាអ្នកទាំងពីរនាក់នេះគឺជា "ស្រមោលទាំងគូ" របស់ប៉ុល ពត ឬ ជាផ្នែកមួយនៃ "បងធំទាំងបី" ទោះបី

យ៉ាងណាក៏ដោយ ឋានានុក្រម បក្សកុម្មុយនីសកម្ពុជា នេះត្រូវ បានច្រាន ចោលដោយក្រុមមេធាវីការពារក្ដីទាំងពីរ ថាមិនអាចរក្សាការពារបន្តទៅទៀត បាននោះ ទេ។ លោក វីកទ័រ កូប៉េ មេធាវីរបស់ លោកនួន ជា បានលើកឡើងថាវាមិនសមហេតុសមផល នោះទេដែលតម្រូវឱ្យមេដឹកនាំកំពូលទទួ លខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយ កម្មាភិបាល ថ្នាក់ទាប ទោះក្នុងរបបណាមួយក៏ដោយ ហើយលោកបានរិះគន់យ៉ាងខ្លាំងចំពោះគំនិតដែលដាក់ បញ្ចូលលោក ខៀវ សំផន នៅក្នុងក្រុម "បងធំទាំងបី" រួមជាមួយនឹង នួន ជា និង ប៉ុល ពត។ លោកស្រី Anta Guissé មេធាវីការពារ លោក ខៀវ សំផន បានច្រានចោលការលើកឡើងស្រដៀង គ្នានេះដែរ ដោយហៅថាជា "ការបកស្រាយឱកាសនិយមបែបថ្មីពីការពិត ពីព្រោះថាស្លាប់ ទៅ ជាទីពិរោះក្នុងសារពត៌មាន"។

## ៣. ការវិភាគលើផ្លូវច្បាប់និងនីតិវិធីក្នុងដំណើរការជំនុំជម្រះ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបាន ដោះស្រាយបញ្ហាផ្លូវច្បាប់យ៉ាង ច្រើនសន្ធឹកសន្ធាប់ក្នុងអំឡុងពេលនៃអត្ថិភាពរបស់ខ្លួន។ បញ្ហាមួយអន្លើកើតចេញពីសភាវៈកូនកាត់ នៃតុលាការមួយនេះ រួមនិងភាពតានតឹងផ្នែកនីតិវិធីនៃការអនុវត្តច្បាប់ស៊ីវិលនិងច្បាប់ទូទៅ។ តុលាការក៏បានប្រឈមនឹងបញ្ហាក្នុងការធ្វើឱ្យមានតុល្យភាពរវាងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ប្រកបដោយប្រសិទ្ធិភាព ខណៈដែលធានាឱ្យមានភាពស្មើគ្នានៃអង្គភាពអយ្យការ និង មេធាវីការពារក្ដី។ ជាការស្មានទុកជាមុនលើសាលក្រមក្នុងសំណុំរឿង ០០២/០២ អ្នកនិពន្ធបានធ្វើ ការវិភាគ បញ្ហាផ្លូវច្បាប់និ ងនីតិវិធីសំខាន់ៗដែលកើតមានឡើងក្នុងកំឡុងសវនាការសំណុំរឿង ០០២/០២តាមរយៈការសង្កេតលើដំណើរការសវនាការដោយក្រុមឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម ដែលមានវត្តមានជារៀងរាល់ថ្ងៃ។

### ក. ការបំបែកដំណើរការនីតិវិធី និងការពង្រីកវិសាលភាព

ដូចដែលបានលើកឡើងខាងលើ ការជំនុំជម្រះដំណាក់កាលទី ២ មានវិសាលភាពដោះស្រាយលើ បញ្ហានិងទីតាំងទូលំទូលាយច្រើនជាងអ្វីដែលត្រូវបានគ្របដណ្ដប់ក្នុងសំណុំរឿង ០០២/០១ ។ នៅ ពេលបញ្ចេក់ពីដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនិងវិសាលភាពមុនថ្ងៃ ៣០ ខែកក្កដា ឆ្នាំ ២០១៤ សវនាការបឋមក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញ ថាការរួមបញ្ចូលគ្នានៃសំណុំរឿង ០០២/០១ ដែលជិតបិទបញ្ចប់នាពេលនោះ ហើយនិងវិសាល ភាពថ្មីនៃសំណុំរឿង ០០២/០២ បានបំពេញតាមស្តង់ដារនៃ "ការបង្ហាញភាពសមហេតុផល" សម្រាប់ការចោទប្រកាន់ពេញលេញ។[11] ជិតពីរឆ្នាំកន្លះក្រោយមកពេលដែលសំណុំរឿង ០០២/០២ ឈានជិតដល់ការបិទបញ្ចប់សវនាការលើភស្តុតាងហើយ

[11] អង្គជំនុំជម្រះតុលាការកំពូល "សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ខៀវ សំផនប្រឆាំ ងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលា ដំបូងស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងការពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០២" (ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០១៤) E301 / 9/1/1/3 ។

នោះ អង្គជំនុំជម្រ ះសាលាដំបូងបានចេញ សេចក្តីសម្រេចកាត់បន្ថយវិសាលភាពនៃសំណុំរឿង ០០២ ដោយបញ្ជាក់ថាសំណុំរឿង ០០២/០២ គឺជាការកាត់ក្តីចុងក្រោយ ប្រឆាំងនឹងមេដឹកនាំជាន់ខ្ព ស់របស់ របប កម្ពុជាប្រជាធិបតេយ្យដែលនៅ រស់រានមានជីវិត។ ថ្វីបើមានការចោទប្រកាន់ជាេ្រ ចីនថាការបិទបញ្ចប់ សំណុំរឿង ០០២/០២ បាន តំណាងឱ្យគ្រប់ភាគីទាំងអស់ក្តី ក៏មានការជំទាស់ និងការយល់ច្រ ឡំលើ វិសាលភាពបើធៀបនឹងសវនាការក្នុងសំណុំរឿង ០០២/០១ ។

គួយ៉ាងនៃការជំទាស់ទាក់ទងនឹងវិសាលភាព គឺពាក់ព័ន្ធនឹងការប៉ុនប៉ងរបស់ការិយាល័ យ សហព្រះរាជអាជ្ញា ក្នុងការដោះស្រាយការប្រព្រឹត្តលើជនជាតិភាគតិចខ្មែរក្រោម ដែលជាការពិត នោះមិនត្រូវបានដាក់បញ្ចូល នៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ តាមការសម្រេចរបស់ ការិយាល័យសហចៅក្រម ស៊ើបអង្កេត។ជាពិសេសក្នុងអំឡុងពេលសវនាការអំពីសហករណ៍ស្រុកត្រាំកក់និងការដាក់គោលដៅលើ ជនជាតិវៀតណាម ការិយាល័យសហព្រះរាជអាជ្ញា បានសួរម្តង ហើយម្តងទៀតអំពីការជួបប្រទះរបស់ ជនជាតិភាគតិចខ្មែរក្រោមដែលជាញឹកញាប់ត្រូវបានចោទប្រកាន់ថាមាន "ក្បាលយួនខ្លួនខ្មែរ"។ បន្ទាប់ពី មានការជំទាស់ និងសំណើសុំរបស់មេធាវីការពារក្តី អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ជំហររបស់ខ្លួនថា ប្រធានបទនេះស្ថិតនៅក្រៅវិសាលភាព ទោះ បីបញ្ហាខ្មែរក្រោមនៅតែត្រូវបានបន្ត លើកយកមកពិភាក្សា រហូតដល់ចុងសប្តាហ៍ទី ៧៤ នៃសវនាការ ក៏ដោយ។ មេធាវីលោកខៀវ សំផនបានលើកហេតុផលថា ការិយាល័យសហព្រះរាជអាជ្ញា មិន ត្រឹមតែព្យាយាម បង្កើតក្រុមគោលដៅថ្មីមួយនៅក្នុងវិសាលភាពនៃ ការជំនុំជម្រះប៉ុណ្ណោះទេ ប៉ុន្តែក៏ កំពុងព្យាយាមប្រើភស្តុតាងទាក់ទងនឹងការប្រព្រឹត្តលើខ្មែរក្រោមផងដែរ ដើម្បីកសាងសំណុំរឿង របស់ខ្លួន សម្រាប់ការកាត់ទោសពីបទប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិ វៀតណាម។[12]

## ខ. ផលប៉ះពាល់នៃការបន្តស៊ើបអង្កេតលើសំណុំរឿង ០០២/០២

ខណៈពេលដែលសំណុំរឿង ០០២/០២ កំពុងបន្តប្រព្រឹត្តទៅ សហចៅក្រមស៊ើបអង្កេតបានកំពុ ង ដំណើរការស៊ើបអង្កេតលើជនសង្ស័យ ៤ នាក់ផ្សេងទៀត។ ការស៊ើបអង្កេតលើការចោទប្រកាន់ មួយចំនួនលើបុគ្គលទាំង ៤រូបនោះ គឺជាន់គ្នាជាមួយបទចោទប្រ កាន់ក្នុងសំណុំរឿង ០០២/០២ ជាពិសេស ការសំដៅទៅលើជនជាតិចាមនៅក្នុងភូមិភាគកណ្តាលនិងការបោសសំអាតកងកម្លាំង បក្សកុម្មុនីស្តកម្ពុជា នៅភូមិភាគនិរតីនិងបូព៌ា។ បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាដែលកើតឡើង ច្រើនបំផុតអង្គជំនុំជម្រះក្នុង សំណុំរឿង ០០២/០២ ជួបប្រទះគឺថាតើគេត្រូវដោះស្រាយជាមួយ ភស្តុតាងដែ លមានប្រភពចេញពី ការស៊ើបអង្កេតទាំងនេះ ប៉ុន្តែមានភាពពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ យ៉ាងដូចម្តេច? ទាំងឯកសារថ្មីនិង

[12] អង្គជំនុំជម្រះសាលាដំបូង "សេចក្តីសម្រេចលើការបន្ថយវិសាលភាពនៃសំណុំរឿង ០០២ (ថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០១៧) និង E439 / 5 យោងតាមលោក Cohen, Mattes, និង McCaffrie, យុត្តិធម៌នៃបណ្តឹងឧទ្ធរណ៍ទំព័រ ១៨។

ចាស់ៗ រួមនិងចម្លើយរបស់កសិណសាក្សី ក៏ដូចជាសាក្សីនិងភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលទើបត្រូវបាន រកឃើញថ្មី។

ការដាក់ភស្តុតាងថ្មីក្នុងអំឡុងពេលជំនុំជម្រះលើកដំបូងអំឡុងដើមសប្តាហ៍ទី ៦ នៃសវនាការលើ ភស្តុតាងបានបង្កឱ្យមានបញ្ហាប្រឈមទាក់ទងនឹងនីតិវិធីនិងសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួល បាន ភស្តុតាងប្រឆាំងនឹងពួកគេ។ ជារឿយៗ ក្រុមមេធាវីការពារក្តីបានសម្តែងការខកចិត្តចំពោះ "ការហូរចូលយ៉ាងគំហុក" នៃភស្តុតាងថ្មី និងបានស្នើឱ្យមានការពន្យារពេលជំនុំជម្រះបន្ថែមទៀត ដើម្បីឱ្យ ពួកគេមានពេលវេលារៀបចំ នៅពេលដែលមានភស្តុតាងថ្មីត្រូវបានដាក់។ នេះក៏ជាបញ្ហា ចោទលើ សមភាពនៃអង្គទាំងពីរ ពោលគឺនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល មានតែភាគីអយ្យការមួយគត់ ដែលមានសិទ្ធ ពិសេសក្នុងការទទួលបានព័ត៌មានពីការស៊ើបអង្កេតដែលកំពុងបន្តធ្វើខណៈ ដែល ភាគីការពារក្តីត្រូវបានហាមឃាត់មិនឱ្យចូលរួម ឬធ្វើការស៊ើបអង្កេតផ្ទាល់ខ្លួននោះ។ យ៉ាងហោច ណាស់ក៏ មានមួយលើកដែរ ដែលមេធាវីលោកនួន ន ជា បានចោទប្រកាន់ ការិយាល័យសហព្រះរាជ អាជ្ញាថាបាន ប្រើប្រាស់ ចំណេះដឹង រឺព័ត៌មានដែលខ្លួនដឹងជាមុនពីការស៊ើបអង្កេតដែលកំពុងបន្ត ដើម្បី ផ្តល់ ព័ត៌មាន យុទ្ធសាស្ត្រនៅក្នុងសំណុំរឿង ០០២/០២ ដែលធ្វើឱ្យប៉ះពាល់ ដល់ប្រយោជន៍ របស់ ជនជាប់ចោទ។ ការិយាល័យសហព្រះរាជអាជ្ញា បានអះអាងថាខ្លួនមានភារកិច្ចបង្ហាញពី ភស្តុតាងដោះបន្ទុកដែលមានសក្តានុពល ជាមួ យជំនួយការព្រះរាជអាជ្ញា ពោលគឺ លោក ឌែល លីសាក (Dale Lysak) ដោយបន្ថែមថា អង្គចៅក្រមមាន «កាតព្វកិច្ចមិនចាំ បាច់ដាក់ខ្លួននៅក្នុងការ ស៊ើបអង្កេតដែលបានធ្វើឡើងកាលពីប៉ុន្មាន ឆ្នាំមុនកន្លងមកនោះទេ»។

## គ. តួនាទីរបស់សាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណី

ក្នុងចំណោមអ្នកផ្តល់សក្ខីកម្ម ១៨៦ នាក់នៅក្នុងសំណុំរឿង ០០២/០២ មានចំនួន ៦៤ រូបជាដើម បណ្តឹងរដ្ឋប្បវេណី - ច្រើនជាងអ្នកចូលរួមក្នុងសំណុំរឿង ០០២/០១ ពីរដង។ ជារួម អ្នកដែល ទទួលជាដើម បណ្តឹងរដ្ឋប្បវេណីចំនួនក្នុងសំណុំរឿង ០០២ ទាំងមូលមានចំនួន ៣.៨៦៩ រូប។ តារាងទី ៣ ខាងក្រោបង្ហាញ តួលេខអ្នកផ្តល់សក្ខីកម្មតាមសំណុំរឿង ០០២/០១, សំណុំរឿង ០០២/០២ និងសំណុំរឿង ០០២ ទាំងមូល:

ប្រភេទនៃការផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២ និងការជំនុំជម្រះបន្ទាប់បន្សំ:

| | សំណុំរឿង ០០២ - ទាំងមូល | | សំណុំរឿង ០០២/០១ | | សំណុំរឿង ០០២/០២ | |
|---|---|---|---|---|---|---|
| ប្រភេទសក្ខីកម្ម | # | % | # | % | # | % |
| សាក្សី | ១៧២ | ៦១.៨៧% | ៥៨ | ៦៣.០៤% | ១១៤ | ៦១.២៩% |
| ដើមបណ្តឹងរដ្ឋប្បវេណី | ៩៥ | ៣៤.១៧% | ៣១ | ៣៣.៧០% | ៦៤ | ៣៤.៤១% |
| អ្នកជំនាញ | ១១ | ៣.៩៦% | ៣ | ៣.២៦% | ៨ | ៤.៣០% |
| សរុប | ២៧៨ | | ៩២ | | ១៨៦ | |

យើងបានមើលឃើញការពិភាក្សាជាច្រើន លើភាពខុសគ្នារវាងដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់សក្ខីកម្មអំពីការឈឺចាប់ និងអ្នកដែលផ្តល់សក្ខីកម្មលើការពិត ៗនៅក្នុងសំណុំរឿង ០០២ ។ អង្គជំនុំ ជម្រះសាលាដំបូងបានផ្លាស់ប្តូរនីតិវិធីនៅក្នុងសំណុំរឿង ០០២/០២ ដើម្បីដោះស្រាយបញ្ហាមួយ ចំនួនដែលរកឃើញនៅក្នុងសំណុំរឿង ០០២/០១ ។ លោកនួន ជាបានជំទាស់នឹងបណ្តឹងសាទុក្ខ នៅក្នុងសំណុំរឿង ០០២/០១ ដែលថាអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តខុសដោយផ្អែកលើ ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីពិនិត្យបញ្ជាក់លើកំហុស ទាំងនៅលើហេតុផលដែលភាគី ដើមបណ្តឹងរដ្ឋប្បវេណី មិនបានស្បថហើយអាចពិ គ្រោះជាមួយមេធាវីរបស់ខ្លួនមុនពេលផ្តល់សក្ខី កម្មដែលខុសគ្នាពីសាក្សី។ តាមរយៈសាលក្រមលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានគាំទ្រលើសេចក្តីវិនិច្ឆ័យដើមដំបូងរបស់អង្គជំនុំជម្រះសាលា ដំបូង លើភស្តុតាងដែលផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណីទោះបីយ៉ាងណាក៏ដោយអង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ចំណុចជាច្រើនដែលអង្គជំនុំជម្រះសាលាដំបូងមិនបានផ្តល់ ការពន្យល់អំពី របៀបដែលខ្លួនបានវាយតម្លៃភស្តុតាងទាំងនោះជាមុននោះទេ។[13]

ដូចដែលបានកត់សម្គាល់ខាងលើ គឺមានភាពខុសគ្នារវាងដើមបណ្តឹងរដ្ឋប្បវេណីដែលចូលរួមក្នុងសវនាការជាពិសេសស្តីពីផលប៉ះពាល់ជនរងគ្រោះ និងអ្នកដែលមានវត្តមាននៅក្នុងសវនាការធម្មតា។ ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីចំនួ ន ៦៤ នាក់ដែលបានផ្តល់សក្ខីកម្មមាន ២៦នាក់ ត្រូវបានកោះហៅដើម្បីផ្តល់សក្ខីកម្មនៅក្នុងសវនាការពិសេសស្តីពីផលប៉ះពាល់ជនរងគ្រោះ។ តាមទ្រឹស្តីសវនាការ

---

[13] សម្រាប់សេចក្តីសង្ខេបនៃសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីខ្មែរក្រោម សូមមើលរបាយការណ៍ឃ្លាំមើល របស់ KRT Trial Monitor ចេញផ្សាយលេខ ២០ លើសំណុំរឿង ០០២/០២ សវនាការលើភស្តុតាងសប្តាហ៍ទី ១៧ (ថ្ងៃទី ២៥-២៨ ខែឧសភា ឆ្នាំ ២០១៥) ទំព័រ ៨។

ទាំងនេះមានបំណងផ្តល់ឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីបង្ហាញពីការឈឺចាប់របស់ពួកគេចំពោះមុខតុលាការ។ ភាគីនានាបានធ្វើការពិភាក្សាលើការកែប្រែទម្រង់ដែលពួកគេ ត្រូវចូលរួម មុនចាប់ផ្តើមបើកសវនាការស្តីពីផលប៉ះពាល់លើជនរងគ្រោះលើកដំបូងក្នុងសំណុំរឿង ០០២/០២ ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់ឱ្យមេធាវីការពារក្តីចោទសួរភាគីដើមបណ្តឹងរដ្ឋប្បវេណី ផងដែរ ដើម្បីដោះស្រាយការរិះគន់មួយចំនួនលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈ សវនាការស្តីពីផលប៉ះពាល់ដល់ជនរងគ្រោះ។ ចំណុចផ្លាស់ប្តូរមួយផ្សេងទៀតដែលមិនដូចគ្នាទៅ នឹងសំណុំរឿង ០០២/០១ គឺដើមបណ្តឹងរដ្ឋប្បវេណីដែលបានបង្ហាញខ្លួនក្នុងសវនាការស្តីពីផល ប៉ះពាល់លើជនរងគ្រោះនៅក្នុងសំណុំរឿង ០០២/០២ ត្រូវបានចោទសួរដោយមេធាវីដើមបណ្តឹង រដ្ឋប្បវេណី ដូចជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានចូលរួមក្នុងសវនការធម្មតា ជាជាងឱ្យពួកគេអាន សេចក្តីថ្លែងនៃការឈឺចាប់។ មានតែមួយលើកប៉ុណ្ណោះដែលដើមបណ្តឹងរដ្ឋប្បវេណី ថន ធីម ដែល បានផ្តល់សក្ខីកម្មក្នុងសវនាការស្តីពីផលប៉ះពាល់ដល់ជនរងគ្រោះ ត្រូវបានអញ្ជើញមកវិញតាមការ ស្នើសុំពីក្រុមមេធាវីការពារក្តីដើម្បីផ្តល់សក្ខីកម្មក្នុងអង្គសវនាការបង្ហាញការពិត ដោយសារមានភាព ពាក់ព័ន្ធទៅនឹងប្រធានបទដែលបានលើកឡើងក្នុងសវនាការអំពីផលប៉ះពាល់ដល់ជនរងគ្រោះ។

## ឃ. ការប្រើប្រាស់ភស្តុតាងដែលអាចទទួលយកបាន

យើងបានមើលឃើញការរំខានលើនីតិវិធីក្នុងដំណើរការជំនុំជម្រះ ចំនួន ១៩ សប្តាហ៍ក្នុងចំណោម ៧៧ សប្តាហ៍ ដោយសារភាគីនានាបានពិភាក្សាអំពីសុពលភាពនៃការប្រើប្រាស់ឬ សក្តានុពលនៃ ការប្រើប្រាស់ឯកសារដែលកើតចេញពីឬទទួលបានតាមរយៈការធ្វើទារុណកម្ម។ បញ្ហានេះត្រូវបាន លើកឡើងជាញឹកញាប់នៅក្នុងផ្នែកមន្ទីរសន្តិសុខស ២១ ប៉ុន្តែមិនមានន័យថាមានត្រឹមតែផ្នែកនេះ មួយមុខគត់ប៉ុណ្ណោះទេ។ ទាំងក្រុមមេធាវីការពារក្តីរបស់ លោកនួន ជា និង ការិយាល័យសហព្រះ រាជអាជ្ញា ត្រូវបានបញ្ឈប់ម្តងហើយម្តងទៀតដោយអង្គចៅក្រម លើការព្យាយាមយោងទៅលើ ឯក សារ ដែលត្រូវបានគេដឹងឬត្រូវបានសន្មតថាទទួលបានតាមរយៈការធ្វើទារុណកម្ម នៅក្នុងសវនា ការ។ អង្គជំនុំជម្រះសាលាដំបូងមិនបានចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ អំពីការប្រើ ប្រាស់ ភស្តុតាងដែលទទួលបានក្រោមរូបភាពធ្វើទារុណកម្មរហូតដល់ខែកុម្ភៈ ឆ្នាំ ២០១៦ ពោលគឺ ច្រើន ជាងពាក់កណ្តាលនៃសវនាការលើភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២។ ដោយមុននេះ អង្គជំនុំ ជម្រះធ្វើការសម្រេចតាមករណីនីមួយៗ និងដោយប្រើប្រាស់សេចក្តីសម្រេចរបស់អង្គជំនុំ ជម្រះ តុលាការកំពូល ជាការចង្អុលបង្ហាញលើឯកសារដែលអាចទទួលយកបានក្នុងសំណុំរឿង ០០២/០១ ។

ដោយមិនមានការវិនិច្ឆ័យច្បាស់លាស់ឬការណែនាំពីអង្គជំនុំជម្រះសាលាដំបូងលើការជំនុំជម្រះដ៏យូរអង្វែងនេះ ភាគីនីមួយៗបានធ្វើការបកស្រាយខុសៗគ្នាក្នុងសំណុំរឿង ០០២/០២ ។ អង្គជំនុំជម្រះ សាលាដំបូង

បានសម្រេចថាចំណុចទាំងពីរនេះ មាត្រា ១៥ នៃអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តលើខ្លួន ឬទណ្ឌកម្មដទៃទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប(**CAT**)[14]និង ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហាមឃាត់តុលាការពីការផ្តល់ទម្ងន់ដល់ សេចក្តីថ្លែងការណ៍ណាមួយដែលទទួលបានតាមរយៈការបង្ខិតបង្ខំ។ សេចក្តីថ្លែងការណ៍ដែលមាន ប្រភពចេញពីមន្ទីរសន្តិសុខ ដែលត្រូវបានគេចាត់ទុកទទួលបានតាមរយៈ ការធ្វើទារុណកម្មនៅនឹង កន្លែង គឺមិនអាចប្រើប្រាស់បានដើម្បីបង្ហាញពីការអត្ថន័យនៃការពិតនៅ អ.វ.ត.ក បានឡើយ។ ព័ត៌ មានជីវប្រវត្តិ ដូចជាឈ្មោះ និងកាលបរិច្ឆេទអាចត្រូវបានប្រើដើម្បីបង្កើតជាមូលដ្ឋាននៃការសាកសួរ ក៏ប៉ុន្តែខ្លឹមសារនៃចម្លើយសារភាពមិនអាចអនុញ្ញាតបានទេ វៀរលែងតែមានការបញ្ជាក់បានច្បាស់ លាស់ថាករណីនីមួយៗនោះមិនជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម។

14 អង្គជំនុំជម្រះតុលាការកំពូល, សាលដីកាលើបណ្តឹងឧទ្ធរណ៍ (ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦), F36, ទំព័រ ១៤១-១៤៩ វាក្យខណ្ឌ ៣០៥-៣២៤